# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សវនាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៩០៧
ចុះថ្ងៃទី ២២-១១-០៦
សាលដីកា
លេខ : ៨៩ "ខ"
ចុះថ្ងៃទី ១៤-០៧-០៩

### អាណាចក្រប្រជារាស្ត្រខ្មែរ
### សាលាឧទ្ធរណ៍ភ្នំពេញ
**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៤-០៧-២០០៩ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៩០៧ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ដែលមាន:

- **ជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កីឡាករប្រដាល់ ធមិថ្នាក់ទី៧ថ្មី កើតនៅសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃ[redacted]ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ[redacted] (រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៩-១២-២០០៥ ឃុំខ្លួនថ្ងៃទី០៣-០១-២០០៦។

លោក[redacted]វិបុល មេធាវីការពារជនជាប់ចោទ។

__**ត្រូវជាប់ចោទពីបទ:**__ ប្លន់ (វាយតំរាមយកប្រាក់សិស្សសាលា) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ តាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- **ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនហេង** ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរនាយករងសាលាឃុំគន្ធរ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៣៣ ផ្លូវ១៦៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក្រុងភ្នំពេញ។

- តាមពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៣៣១ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] **វិច្ឆិកា** ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៧ ឋ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ដែលជំនុំជម្រះទាំងមូលនៃសេចក្ដីសម្រេច។ ៩

១៨៥

**ដំណើររឿងមានដូចតទៅ:**

កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ វេលាម៉ោង៨ព្រឹក ជនល្មើសឈ្មោះ [redacted] វិច្ឆិកា ភេទប្រុស អាយុ ១៩ឆ្នាំ បានធ្វើសកម្មភាពវាយលើជនរងគ្រោះឈ្មោះ [redacted] សុភ័ក្ត្រ ដែលបានដើរចេញពីក្នុងសាលារៀនព្រះយុគន្ធរយកលុយអស់ ៣.៥០០រៀល ហើយជនល្មើសរូបនោះគេចខ្លួនបានតែម្តង។ លុះស្មែកឡើង នាយកសាលាបាននាំជនល្មើសរូបនោះមក ប្រគល់ឱ្យសមត្ថកិច្ចនគរបាលប៉ុស្តិ៍តែម្តង។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៧ ឋ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១- ផ្តន្ទាទោសឈ្មោះ [redacted] វិច្ឆិកា ភេទប្រុស អាយុ ១៩ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ពីបទ ប្លន់ (វាយគំរាមយកប្រាក់សិស្សសាលា) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹង [redacted] ប៊ុនហេង (នាយកសាលាព្រះយុគន្ធរ) បើកសិទ្ធិឱ្យប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៣១ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] វិច្ឆិកា ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៧ ឋ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ចៅក្រមអានរបាយការណ៍រឿង

ជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា ឆ្លើយថា: ពេលប្រព្រឹត្ត ខ្លួនមានអាយុ ២០ឆ្នាំ ខ្លួនដឹងទោសកំហុសរបស់ខ្លួន ហើយខ្លួនទទួលស្គាល់ថាបានប្រព្រឹត្ត ហើយខ្លួនប្តឹងឧទ្ធរណ៍មក សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

ប្រធានអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយនៅតុលាការក្រុងភ្នំពេញ។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

តាមអង្គហេតុ និងតាមបណ្តឹងរបស់ជនរងគ្រោះចំនួន៥នាក់ ដែលជាសិស្សសាលាបានអះអាងថា ជនល្មើសឈ្មោះ [redacted] វិច្ឆិកា ពិតជាបានគម្រាមកំហែង និងសម្តីសំឡុតផ្តែកស្មារតី យកលុយពីពួកខ្លួនពិតប្រាកដមែន ទាំងនេះឃើញថា មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ [redacted] វិច្ឆិកា ពីបទ ប្លន់។

ហេតុដូច្នេះ មហាអយ្យការសូមសន្និដ្ឋាន:

១- ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] វិច្ឆិកា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៧ ឋ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

តាមការសួរដេញដោលពេលនេះ កូនក្តីខ្លួនបានសារភាពថា បានប្រព្រឹត្តមែន តែសូមលោកប្រធានពិចារណាទៅលើព្យសនកម្ម និងសុំបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយអនុគ្រោះ ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ៣៣១ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] វិច្ឆិកា ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ វេលាម៉ោង៨ព្រឹក ខ្លួនពិតជាបានវាយឈ្មោះ [redacted] ច័ន្ទសុភ័ក្ត យកលុយនៅពេលដែលឈ្មោះនេះចេញពីសាលាព្រះយុគន្ធរ យកបានប្រាក់ចំនួន ៣.៥០០រៀល រួចគេចខ្លួនមែន នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៥ វេលាម៉ោង១និង៣០នាទី ខ្លួនវាយសិស្សសាលាព្រះយុគន្ធរយកលុយទៀត តែត្រូវនាយកសាលាឃាត់ខ្លួន បញ្ជូនទៅសមត្ថកិច្ច ។ ខ្លួនធ្លាប់វាយសិស្សយកលុយជាច្រើនលើក មិនចាំទេ ។

៣- មានពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ប្លន់ (វាយយកលុយ) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ មាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៨៧ ឋ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៣១ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៦ របស់ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៧ ឋ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ ដោយគ្រាន់តែកែប្រែកម្រិតទណ្ឌកម្មដាក់ពន្ធនាគារពី ៥ឆ្នាំ មក ៤ឆ្នាំ ៨ខែ វិញ គិតពីចាប់ខ្លួន ។

១៤៧

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីការនេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី[illegible] ខែ 02 ឆ្នាំ២០១4
ក្រឡាបញ្ជី
[redacted]

១៨៨